


# ការពិនិត្យមើលផ្ទៀងផ្ទាត់តាមអេឡិចត្រូនិច

## ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS

## ការចុះឈ្មោះអ្នកទទួលជំនួយ

សម្រាប់ជំនួយបន្ថែម សូមទាក់ទងទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS តាមលេខទូរស័ព្ទ (866) 376-7066 នៅពេលម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ពីម៉ោង 8am ទៅម៉ោង 5pm ។



ដើម្បីចុះឈ្មោះសំរាប់ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការ (TTS) នៃកម្មវិធី IHSS សូមចុច (833) DIAL-EVV ឬ (833) 342-5388 ហើយ អ្នកនឹងឮសារសម្លេងដូចខាងក្រោមនេះ:

**"សូមអរគុណចំពោះអ្នកក្នុងការទូរស័ព្ទមកប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS ។ សូមជ្រើសរើសយកភាសាដែលអ្នកចូលចិត្តពីជម្រើសខាងក្រោម អ្នកអាចធ្វើការជ្រើសរើសរបស់អ្នក នៅពេលណាក៏បាន ។"**

ដោយការធ្វើតាមការណែនាំខាងក្រោម សូមប្រើកូនប្រអប់វាយ (keypad) លេខទូរស័ព្ទរបស់អ្នក ដើម្បីបញ្ចូលព័ត៌មានដែលអ្នកចង់បាន ។

**សំរាប់ភាសា អង់គ្លេស សូមចុចលេខ 1 ។**

**សំរាប់ភាសា អេស្ប៉ាញ សូមចុចលេខ 2 ។**

**សំរាប់ភាសា អាមីនៀន សូមចុចលេខ 3 ។**

**សំរាប់ភាសាចិន សូមចុចលេខ 4 ។**

បន្ទាប់មក កម្មវិធី TTS នឹងសួរអ្នកដើម្បីបញ្ជាក់ថាតើអ្នកគឺជា អ្នកផ្តល់សេវា ឬអ្នកទទួលជំនួយ ។

**"បើអ្នកគឺជា អ្នកទទួលជំនួយ សូមចុចលេខ '1', បើអ្នកគឺជា អ្នកផ្តល់សេវា សូមចុចលេខ '2' ។"**

អ្នក នៅពេលនេះនឹងត្រូវបាននាំយកទៅកាន់ម៉ឺនុយដើមដំបូង (Main Menu) ។

**"នេះគឺជាម៉ឺនុយដើមដំបូង ។ សូមជ្រើសរើសយកពីជម្រើសដូចតទៅនេះ ។ អ្នកអាចធ្វើការជ្រើសរើសរបស់អ្នក នៅពេលណាក៏បាន:**

**សូមចុចលេខ 1 ដើម្បីចូលបណ្តាញ**

**សូមចុចលេខ 2 ដើម្បីកំណត់ឡើងវិញនូវលេខកូដសម្ងាត់របស់អ្នក**

**សូមចុចលេខ 3 សំរាប់ការចុះឈ្មោះ"**

សំរាប់ផ្នែកបន្ទាប់ អ្នកនឹងត្រូវការមានព័ត៌មានដូចខាងក្រោម ដែលបានរៀបចំរួចជាស្រេច និងអាចប្រើប្រាស់បាន ។

- លេខកូដចុះឈ្មោះ 6 ខ្ទង់ របស់អ្នក ។
  - លេខកូដចុះឈ្មោះរបស់អ្នកគឺត្រូវបានផ្ញើទៅជូនអ្នកពីពេលមុន ។ បើសិនជាអ្នកមិនអាចរកវាឃើញនោះទេ សូមទំនាក់ទំនងទៅការិយាល័យខោនធីក្នុងតំបន់របស់អ្នក ។
- លេខអ្នកទទួលជំនួយរបស់អ្នក ។
  - លេខអ្នកទទួលជំនួយរបស់អ្នកគួរតែជាតួលេខ 7 ខ្ទង់ ហើយដែលអាចរកឃើញនៅលើសេចក្តីប្រកាសជូនដំណឹងរបស់អ្នក ។
- កាលបរិច្ឆេទកំណើត ។

បន្ទាប់មក កម្មវិធី TTS នឹងរំលឹកប្រាប់អ្នកថា:

**"ដើម្បីបន្ត សូមចុចលេខ 1 ។"**

**"ដើម្បីត្រឡប់ទៅម៉ឺនុយដើមដំបូង សូមចុចលេខ 9 ។"**

**"បើសិនជាអ្នកមិនមានលេខកូដចុះឈ្មោះទេ សូមចុចលេខ 0 សំរាប់ជំនួយ ។"**

បើសិនជាអ្នកចុចលេខ 0 អ្នកនឹងត្រូវបានបញ្ជូនទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS ។

**"ដោយប្រើកូនប្រអប់វាយលេខទូរស័ព្ទរបស់អ្នក សូមបញ្ចូលលេខកូដចុះឈ្មោះ 6 ខ្ទង់របស់អ្នក ហើយចុចសញ្ញាទ្រុងជ្រូក (#) ។ លេខកូដចុះឈ្មោះរបស់អ្នក ត្រូវបានផ្ញើទៅឱ្យអ្នក កាលពីកាលបរិច្ឆេទមុន ។"**

**"សូមបញ្ចូលលេខសំណុំរឿង 7 ខ្ទង់របស់អ្នក ហើយចុចសញ្ញាទ្រុងជ្រូក (#) ។ លេខសំណុំរឿងរបស់អ្នក គឺរកឃើញនៅលើសេចក្តីប្រកាសជូនដំណឹងណាមួយដែលអ្នកបានទទួល ។"**

**"សូមបញ្ចូលកាលបរិច្ឆេទកំណើតរបស់អ្នក ហើយចុចសញ្ញាទ្រុងជ្រូក (#) ។" កាលបរិច្ឆេទកំណើតរបស់អ្នកគួរតែបញ្ចូលជា លេខ 2 ខ្ទង់សំរាប់ខែ លេខ 2 ខ្ទង់សំរាប់ថ្ងៃ និង លេខ 4 ខ្ទង់សំរាប់ឆ្នាំ ។ ឧទាហរណ៍ បើកាលបរិច្ឆេទកំណើតរបស់អ្នកគឺជាថ្ងៃទី 12 ខែឧសភា ឆ្នាំ 1976, ដូច្នេះ អ្នកនឹងត្រូវបញ្ចូលលេខ 0 5 1 2 1 9 7 6 ។ សូមបញ្ចូលកាលបរិច្ឆេទកំណើតរបស់អ្នក ហើយចុចសញ្ញាទ្រុងជ្រូក (#) ។"**

ឧទាហរណ៍: ថ្ងៃទី 01 ខែឧសភា ឆ្នាំ 2019

**ខែ: ឧសភា** **ថ្ងៃ: 01** **ឆ្នាំ: 2019#**




ប្រសិនបើអ្នកបញ្ចូលលេខណាមួយមិនត្រឹមត្រូវ កម្មវិធី TTS នឹងប្រាប់ឱ្យអ្នកដឹងថាព័ត៌មាននេះគឺមិនត្រឹមត្រូវទេ ហើយនឹងប្រាប់ឱ្យអ្នកវាយបញ្ចូលលេខទាំងនោះម្តងទៀត ។

ប្រសិនបើអ្នកបញ្ចូលលេខទាំងនោះមិនត្រឹមត្រូវម្តងទៀត, កម្មវិធី TTS នឹងប្រាប់ឱ្យអ្នកចុចលេខ 0 សំរាប់ជំនួយ ។ អ្នកនឹងត្រូវបានបញ្ជូនទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS ។

នៅពេលដែលអ្នកបញ្ចូលលេខទាំងនោះបានត្រឹមត្រូវរួចហើយ អ្នកនឹងឮសារសម្លេងដូចតទៅនេះ:

**"ព័ត៌មានរបស់អ្នកត្រូវបានបញ្ជាក់បន្ថែមហើយ ។ ឥឡូវនេះ អ្នកនឹងត្រូវបង្កើតលេខកូដសម្ងាត់របស់អ្នក ។ លេខកូដសម្ងាត់របស់អ្នកនឹងត្រូវជាលេខ 4 ខ្ទង់ ដែលអ្នកនឹងប្រើ នៅរៀងរាល់ពេលដែលអ្នកចូលទៅក្នុងប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS ។ ដោយប្រើកូនប្រអប់វាយលេខទូរស័ព្ទរបស់អ្នក សូមបញ្ចូលលេខ 4 ខ្ទង់ ដែលអ្នកចង់ប្រើធ្វើជាលេខកូដសម្ងាត់របស់អ្នក ហើយចុចសញ្ញាទ្រុងជ្រូក (#) ។"**

សូមចងចាំក្នុងការរក្សាទុក លេខកូដសម្ងាត់របស់អ្នកឱ្យមានសុវត្ថិភាព ហើយ មិនត្រូវប្រាប់ឬបង្ហាញឱ្យនរណាម្នាក់ដឹងឡើយ ។

នៅពេលដែលអ្នកបំពេញផ្នែកលេខកូដសម្ងាត់រួចហើយ អ្នកនឹងឮ:

**"សូមអបអរសាទរ! ការចុះឈ្មោះរបស់អ្នកត្រូវបានបំពេញរួចហើយ និងក្នុងពេលឥឡូវនេះ អ្នកត្រូវបានចុះឈ្មោះដើម្បីប្រើប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS ហើយ ។ ឥឡូវនេះ អ្នកនឹងត្រូវបាននាំយកទៅកាន់ម៉ឺនុយដើមដំបូង ដើម្បីចូលទៅបណ្តាញ ឬ អ្នកអាចដាក់ទូរស័ព្ទចុះ ដើម្បីបញ្ចប់ការហៅទូរស័ព្ទនេះ ។"**

ឥឡូវនេះ អ្នកអាចប្រើលេខកូដសម្ងាត់របស់អ្នក និង ស្វែងរុករកតាមរយៈ TTS ដើម្បីពិនិត្យឡើងវិញ យល់ព្រម ឬ បដិសេធ ម៉ោងដែលអ្នកផ្តល់សេវារបស់អ្នក បានធ្វើការឱ្យអ្នក ។

វាគឺជាការសំខាន់ដែលអ្នកត្រូវរក្សាទុក លេខកូដសម្ងាត់របស់អ្នកឱ្យមានសុវត្ថិភាព ហើយ មិនត្រូវប្រាប់ឬបង្ហាញឱ្យដឹងនូវលេខកូដសម្ងាត់របស់អ្នកឡើយ ។

នេះបញ្ចប់ដំណើរការនៃការចុះឈ្មោះអ្នកទទួលជំនួយ សម្រាប់ការពិនិត្យមើលផ្ទៀងផ្ទាត់តាមអេឡិចត្រូនិចនៃប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការ (EVV TTS) ។ សូមចងចាំថា ក្នុងនាមជាអ្នកទទួលជំនួយ អ្នកក៏អាចធ្វើកិច្ចការដូចតទៅនេះ នៅក្នុងកម្មវិធី TTS បានផងដែរ:

- ពិនិត្យឡើងវិញ និង ចាត់វិធានការនៅលើទំព័រកត់ត្រាពេលម៉ោងធ្វើការ ណាមួយដែលរង់ចាំការសម្រេច និង
- ពិនិត្យឡើងវិញនូវចំណាត់ការដែលបានយល់ព្រម ឬ បដិសេធពីពេលមុន ដែលអ្នកបានធ្វើឡើងនៅលើទំព័រកត់ត្រាពេលម៉ោងធ្វើការ សំរាប់រយៈពេលបី (3) ខែមុន ។